ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣ ❋ ៤៤

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៦១ សជណ.ធទឧ

## សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាព និងឥទ្ធិពលរបស់ព្យុះ រ៉ាម៉ាសាន់

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេតតាមដានលើស្ថានភាពអាកាសធាតុរួចមកឃើញថា នៅវេលាម៉ោង 07 h 00 ព្រឹក ថ្ងៃទី 15 ខែកក្កដា ឆ្នាំ 2014 នេះ ព្យុះទី 9 ឈ្មោះ **រ៉ាម៉ាសាន់ (RAM MASUN)** កំពុងស្ថិតនៅតំបន់ឆ្នេរប្រទេសហ្វីលីពីន ភាគខាងកើត ត្រង់ចំណុចខ្សែស្របទី 12 អង្សា 7 នៃរយៈទទឹងខាងជើង និងខ្សែវ័ណ្ឌទី 125 អង្សា 6 នៃរយៈបណ្តោយខាងកើត ។

យោងតាមការព្យាករណ៍ ព្យុះ **រ៉ាម៉ាសាន់** នឹងធ្វើដំណើរទៅដល់តំបន់ឆ្នេរប្រទេសវៀតណាម ភាគខាងជើង នៅម៉ោងប្រមាណ 19 h 00 យប់ នាថ្ងៃទី 20 ខែកក្កដា ឆ្នាំ 2014 ។ ព្យុះ **រ៉ាម៉ាសាន់** នឹងមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា និងតំបន់ផ្ទៃរងទឹកភ្លៀងទន្លេមេគង្គ ដោយបង្កឱ្យ :

- **សម្រាប់ប្រទេសកម្ពុជា** :
  - **១- តំបន់មាត់សមុទ្រ :** មានភ្លៀងពីបង្គួរទៅច្រើន មានខ្យល់បក់បោកខ្លាំង ពីថ្ងៃទី 18 ដល់ថ្ងៃទី 21 ខែកក្កដា ឆ្នាំ 2014 ។ រលកសមុទ្រមានកំពស់ពី 1 m ទៅ 2,50 m ។
  - **២- តំបន់ខ្ពង់រាប និងតំបន់ទំនាបកណ្តាល :** មានភ្លៀងធ្លាក់ពីមធ្យមទៅច្រើន ចាប់ពីថ្ងៃទី 20 ដល់ថ្ងៃទី 22 ខែកក្កដា ឆ្នាំ 2014 ។
- **ផ្ទៃរងទឹកភ្លៀងទន្លេមេគង្គ :** តំបន់ផ្ទៃរងទឹកភ្លៀងទន្លេមេគង្គ ក្នុងប្រទេសថៃ និងឡាវ នឹងមានភ្លៀងធ្លាក់ច្រើន ចាប់ពីថ្ងៃទី 20 ដល់ថ្ងៃទី 22 ខែកក្កដា ឆ្នាំ 2014 ដែលអាចបង្កឱ្យទឹកទន្លេមេគង្គហក់ឡើង ។

យោងតាមការព្យាករណ៍ស្ថានភាពអាកាសធាតុខាងលើនេះ សូមសាធារណជន ពិសេសបងប្អូនប្រជានេសាទសមុទ្រ និងអ្នកធ្វើដំណើរតាមជលយានទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងត្រូវបង្កើនការប្រុងប្រយ័ត្នឱ្យបានខ្ពស់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានជាយថាហេតុ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh